# កម្មវិធីការងាររបស់ក្រុមមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា
# សំរាប់
# ការវាយតម្លៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ២០១០-២០១១

កម្មវិធីការងារសំរាប់ការវាយតម្លៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ២០១០-២០១១ នៅតាមគ្រឹះស្ថានឧត្តមសិក្សានានា ចែកចេញជា ៣ដំណាក់កាលគឺ:

១-ដំណាក់កាលទី១: មានរយៈពេល ២ថ្ងៃ គឺជាដំណាក់កាលសិក្សាឯកសារដែលក្នុងនោះក្រុមមន្ត្រីវាយតម្លៃគុណភាពអប់រំត្រូវសិក្សារបាយការណ៍ស្វ័យវាយតម្លៃ ដែលបានដាក់ស្នើរ ដោយគ្រឹះស្ថានឧត្តមសិក្សាមក គ.ទ.ក.ដើម្បីសុំការចុះវាយតម្លៃលើដំណើរបណ្ដុះណាល្ដថ្នាក់ឆ្នាំសិក្សមូលដ្ឋានរបស់ខ្លួន។

២-ដំណាក់កាលទី២: មានរយៈពេល ៣ថ្ងៃ គឺជាដំណាក់កាលចុះវាយតម្លៃ ដែលក្នុងនោះក្រុមមន្ត្រីវាយតម្លៃគុណភាពអប់រំ ចុះពិនិត្យផ្ទៀងផ្ទាត់ផ្ទាល់នៅតាម គ្រឹះស្ថានឧត្តមសិក្សា។ (សូមមើលកាលវិភាគសកម្មភាពការងារដូចបានជូនភ្ជាប់)

៣-ដំណាក់កាលទី៣: មានរយៈពេល ១ថ្ងៃ គឺជាដំណាក់កាលបូកសរុបលទ្ធផលនៃការវាយតម្លៃ និងធ្វើរបាយការណ៍របស់ ក្រុមមន្ត្រីវាយតម្លៃគុណភាពអប់រំ ដើម្បីដាក់ជូនទៅគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាពិនិត្យ និងសំរេច។

កាលវិភាគសំរាប់ពេលចុះវាយតម្លៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅតាមគ្រឹះស្ថានឧតម្គសិក្សា

សកម្មភាព ថ្ងៃទី ១

| ពេលវេលា | សកម្មភាព | ការពិពណ៌នាលំអិត | អ្នកចូលរួម |
|---|---|---|---|
| ៨.៣០ ព្រឹក | ការជួបប្រជុំជាមួយតំណាងគ្រឹះស្ថានឧត្តមសិក្សា (ការប្រជុំរៀបចំជាលក្ខណៈការប្រជុំតុមូល) | - មតិស្វាគមន៍ពីតំណាងគ្រឹះស្ថានឧត្តមសិក្សា<br>- តំណាងគ្រឹះស្ថានឧត្តមសិក្សាណែនាំពីការងារគ្រប់គ្រង និង សមាជិក សមាជិការជូនដល់ក្រុមមន្ត្រីវាយតម្លៃ<br>- ប្រធានក្រុមមន្ត្រីវាយតម្លៃបង្ហាញជូននូវគោលបំណងសង្ខេប ពីការចុះធ្វើការវាយតម្លៃនិងណែនាំសមាជិកក្រុម | - សាកលវិទ្យាធិការ / នាយក/សាកលវិទ្យាធិការរង /នាយករង<br>- ប្រធានដេប៉ាតឺម៉ង់<br>- ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង<br>- មន្ត្រីពាក់ព័ន្ធ<br>- ក្រុមមន្ត្រីវាយតម្លៃ |
| ៩.០០ ព្រឹក | ការស្តាប់របាយការណ៍សង្ខេបស្តីពីស្ថានភាពទូទៅនៃដំណើរការថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | - ការរាយការណ៍សង្ខេបរបស់ប្រធានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានអំពីស្ថានភាពទូទៅ<br>- វេទិការសំណួរចំលើយដើម្បីបញ្ជាក់បន្ថែម | - សាកលវិទ្យាធិការ / នាយក/សាកលវិទ្យាធិការរង /នាយករង<br>- ប្រធានដេប៉ាតឺម៉ង់<br>- អ្នកសម្របសម្រួលវគ្គសិក្សា<br>- មន្ត្រីពាក់ព័ន្ធផ្សេងៗ<br>- ក្រុមមន្ត្រីវាយតម្លៃ |
| ១០.០០ ព្រឹក | ការពិនិត្យផ្ទៀងផ្ទាត់របាយការណ៍ និងឯកសារ | - មន្ត្រីវាយតម្លៃពិនិត្យ ផ្ទៀងផ្ទាត់លើរបាយការណ៍ និង ឯកសារដែល បានដាក់បង្ហាញនៅគ្រឹះស្ថានឧត្តមសិក្សា<br>- តំណាងគ្រឹះស្ថានឧត្តមសិក្សា ឬ ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ផល្តល់ឯកសារបន្ថែមតាមការស្នើសុំរបស់មន្ត្រីវាយតម្លៃ | - ក្រុមមន្ត្រីវាយតម្លៃ |

| | | | |
|---|---|---|---|
| ១២.០០ ព្រឹក | សំរាក | | |
| ០២.៣០ ល្ងាច | ការជួបប្រជុំតុមូលជាមួយនិស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | - មន្ត្រីវាយតម្លៃសាកសួរ និងពិភាក្សាជាមួយនិស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋានអំពីការសិក្សា ការប្រឹក្សាលើការសិក្សា ការផ្តល់ជំនួយ ខាងហិរញ្ញវត្ថុ សេវាសុខភាព ការវាយតម្លៃរបស់និស្សិតចំពោះ កម្មវិធីសិក្សា និងការវាយតម្លៃលើការបង្រៀន តួនាទីរបស់និស្សិត និង ការរំពឹងទុករបស់និស្សិតនៅក្នុងការរៀបចំធ្វើផែនការរបស់ គ្រឹះស្ថានឧត្តមសក្សា ការអនុវត្តន៍ និងការវាយតម្លៃ។ល។ | - និស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមកពីគ្រប់វិស័យដោយមានការជ្រើសរើសដោយស្មើភាព និងសមធម៌<br>- ក្រុមមន្ត្រីវាយតម្លៃ |
| ០៤.០០ ល្ងាច | ការចុះពិនិត្យមើលសម្ភាររូបវន្តតាមរយៈការបង្ហាញ របស់និស្សិត | - ក្រុមមន្ត្រីវាយតម្លៃ ចុះពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃសម្ភាររូបវន្ត ប្រើប្រាស់សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដូចជា បន្ទប់សិក្សា បន្ទប់អនុវត្ត បន្ទប់កំព្យូទ័រ បណ្ណាល័យ និងកន្លែងស្នាក់នៅ។ល។ | - និស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋានដែលស្ម័គ្រចិត្ត<br>- ក្រុមមន្ត្រីវាយតម្លៃ |

សកម្មភាព ថ្ងៃទី ២

| ពេលវេលា | សកម្មភាព | ការពិពណ៌នាលំអិត | អ្នកចូលរួម |
|---|---|---|---|
| ៨.៣០ ព្រឹក | ការចុះពិនិត្យមើលសម្ភាររូបវន្តតាមរយៈការបង្ហាញរបស់និស្សិត ( បន្ត) | - ក្រុមមន្ត្រីវាយតម្លៃ ចុះពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃ សម្ភាររូបវន្ត ប្រើប្រាស់សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដូចជា បន្ទប់សិក្សា បន្ទប់អនុវត្ត បន្ទប់កុព្យូទ័រ បណ្ណាល័យ និង បន្ទប់ស្នាក់នៅ។ល។ | - និស្សិតថ្នាក់ឆ្នាំសិក្សាមូល ដ្ឋានដែលស្ម័គ្រចិត្ត<br>- ក្រុមមន្ត្រីវាយតម្លៃ |
| ៩.០០ ព្រឹក | ការប្រជុំពិភាក្សារបស់មន្ត្រីវាយតម្លៃ | - មន្ត្រីវាយតម្លៃប្រជុំពិភាក្សា និងពិនិត្យផ្ទៀងផ្ទាត់ លើរបាយការណ៍ និងឯកសារផល្តជូនដោយគ្រឹះស្ថានឧត្តមសិក្សាជាមួយនឹងទិន្នន័យ ដែលទទួលបានជាក់ស្តែង | - ក្រុមមន្ត្រីវាយតម្លៃ |

| | | | |
|---|---|---|---|
| ១០.០០ព្រឹក | ការជួបប្រជុំតុមូលជាមួយគ្រូបង្រៀនថ្នាកផ្ទាំសិក្សាមូលដ្ឋាន | - មន្ត្រីវាយតម្លៃសាកសួរ និងពិភាក្សាជាមួយគ្រូបង្រៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋានលើការអនុវត្តកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាវិធីសាស្ត្របង្រៀន ការវាយតម្លៃការសិក្សារបស់និស្សិត និងការវាយតម្លៃ លើការបង្រៀន ការលើកទឹកចិត្តការអភិវឌ្ឍន៍សមត្ថភាពការ រៀបចំធ្វើផែនការយុទ្ធសាស្ត្ររបស់គ្រឹះស្ថានឧត្តមសិក្សា ការអនុវត្តន៍ និងការវាយតម្លៃ។ល។ | - គ្រូបង្រៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមានគ្រូពេញម៉ោង និងក្រៅម៉ោង (យ៉ាងតិច១ រូបសម្រាប់មុខវិជ្ជានីមួយៗ)<br>- ក្រុមមន្ត្រីវាយតម្លៃ |
| ១២.០០ ព្រឹក | សំរាក | | |
| ០២.៣០ ល្ងាច | ការប្រជុំតុមូលជាមួយនាយកប្រតិបត្តិរបស់គ្រឹះស្ថាន ឧត្តមសិក្សា អ្នកទទួលខុសត្រូវវគ្គសិក្សាមន្ត្រីទទួល ខុសត្រូវកិច្ចការសិក្សា និងមន្ត្រីពាក់ព័ន្ធផ្សេងៗ | កិច្ចពិភាក្សាផ្តោតលើ:<br>- នីតិវិធីជ្រើសរើសគ្រូបង្រៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ការតំឡើងឋានៈ ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍សមត្ថភាព<br>- ការគ្រប់គ្រង និងការចាត់ចែង សមាជិកក្រុមប្រឹក្សាមហាវិទ្យាល័យ សិទ្ធិអំណាច និងការទទួលខុសត្រូវ<br>- ការអនុវត្តកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន<br>- ការរៀបចំធ្វើផែនការយុទ្ធសាស្ត្ររបស់គ្រឹះស្ថានឧត្តមសិក្សាការអនុវត្តន៍ និងការវាយតម្លៃ<br>- ដំណើរការនៃការចុះឈ្មោះចូលរៀន ។ល។ | - សាកលវិទ្យាធិការ / នាយក/សាកលវិទ្យាធិការ រង /នាយករង<br>- ប្រធានដេប៉ាតឺម៉ង់<br>- មន្ត្រីទទួលខុសត្រូវចុះបញ្ជីនិស្សិត<br>- មន្ត្រីទទួលខុស ត្រូវកិច្ចការសិក្សា<br>- ព្រឹទ្ធបុរស /ព្រឹទ្ធបុរសរង<br>- មន្ត្រីពាក់ព័ន្ធផ្សេងៗ<br>- ក្រុមមន្ត្រីវាយតម្លៃ |

សកម្មភាព ថ្ងៃទី ៣

| ពេលវេលា | សកម្មភាព | ការពិពណ៌នាលំអិត | អ្នកចូលរួម |
|---|---|---|---|
| ០៨.៣០ ព្រឹក | ការប្រជុំរបស់មន្ត្រីវាយតម្លៃ | - មន្ត្រីវាយតម្លៃបូកសរុបលទ្ធផលនៃការវាយតម្លៃជាជំហានដំបូង<br>- ប្រធានក្រុមមន្ត្រីវាយតម្លៃប្រមូលលទ្ធផលនៃការវាយតម្លៃដើម្បីរាយការណ៍ជូនគ្រឹះស្ថានឧត្តមសិក្សា | - ក្រុមមន្ត្រីវាយតម្លៃ |
| ១០.០០ ព្រឹក | ការជួបប្រជុំជាមួយតំណាងគ្រឹះស្ថានឧត្តមសិក្សា | - ប្រធានក្រុមមន្ត្រីវាយតម្លៃធ្វើការបង្ហាញពីរបាយការណ៍សង្ខេបស្តីពី លទ្ធផល នៃការវាយតម្លៃ<br>- ប្រធានក្រុម និងមន្ត្រីវាយតម្លៃបង្ហាញពីចំនុចខ្លាំង និងចំនុចខ្វះខាត និងផល្តុ អនុសាសន៍កែលំអ<br>- ការបំភ្លឺបន្ថែមរបស់គ្រឹះស្ថានឧត្តមសិក្សា<br>- សំណួមពរផ្សេងៗ | - សាកលវិទ្យាធិការ / នាយក/សាកលវិទ្យាធិការរង /នាយករង<br>- ប្រធានដេប៉ាតឺម៉ង់<br>- ព្រឹទ្ធបុរស /ព្រឹទ្ធបុរសរង<br>- មន្ត្រីពាក់ព័ន្ធផ្សេងៗ<br>- ក្រុមមន្ត្រីវាយតម្លៃ |
| ១១.៣០ព្រឹក | បញ្ចប់ការចុះវាយតម្លៃ | | |

<u>កំណត់សំគាល់</u> : ដំណើរការវាយតម្លៃនៅថ្ងៃទី៣ អាចបន្តល់ពេលរសៀល ប្រសិនបើការវាយតម្លៃពុំទាន់ចប់សព្វគ្រប់។

រៀបចំដោយ

នាយកដ្ឋានស្តង់ដា និងទទួលស្គាល់គុណភាពអប់រំ